# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

Core facts / well-founded / prove

(48)

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៣២
ចុះថ្ងៃទី៣១-០៨-២០១៧

សាលដីកា
លេខ: ១០ ក្រVI.ត.ស
ចុះថ្ងៃទី២៧-០១-២០២១

2016 / April
2017 / Aug Trial
Jan / 2021. Appeal
(5 years)

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ដោយមាន ៖

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៣២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted]វុទ្ធី ហៅ ធី ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករអារឈើ មានទីកន្លែងកំណើតនៅភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅ[redacted] កន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ [redacted] ឬ [redacted] មានកូន ០៣នាក់ ទោសពីមុន គ្មាន។ <u>ប្តឹងឧទ្ធរណ៍</u>

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៨ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។

មានមេធាវី [redacted]ភូ ការពារសិទ្ធិឱ្យជនជាប់ចោទ។

២-ជនជាប់ចោទឈ្មោះ [redacted]យឿង ហៅ អាយួន ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងធ្វើផ្ទះ មានទីកន្លែងកំណើតនៅភូមិអញ្ចាញ ឃុំចេកចូក ស្រុកបូរីជលសារ ខេត្តតាកែវ ទីលំនៅមុនពេលឃុំខ្លួនភូមិផ្សារ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ[redacted]មានកូន ០៦នាក់ ទោសពីមុន គ្មាន។ <u>ប្តឹងឧទ្ធរណ៍</u>

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥០២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។



02-02-2021

មានមេធាវី [redacted] , មេធាវី [redacted] និងមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ។

៣-ជនជាប់ចោទឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិបឹកព្រៃធំ ឃុំពេជ្រសារ ស្រុកកោះអណ្តែត ខេត្តតាកែវ ទីលំនៅមុនពេលគេចខ្លួននៅភូមិ [redacted] ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុន គ្មាន។ (គេចខ្លួន)

<u>ជាប់ចោទពីបទ:</u> លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និង បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៤-ជនជាប់ចោទឈ្មោះ [redacted] ស្រីស្ងួត ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីកន្លែងកំណើតនៅភូមិក្រាំងល្ពង ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃុំខ្លួន [redacted] ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) ប្តីឈ្មោះ [redacted] ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៤១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦។

<u>ជាប់ចោទពីបទ:</u> **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និង បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ៣៥៣ មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៥-ជនជាប់ចោទឈ្មោះ [redacted] ម៉ុន្ថា ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ យោធា មានទីកន្លែងកំណើតនៅភូមិព្រៃសាគុំ ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ទីលំនៅ [redacted] ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ ទោសពីមុន គ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។



Scanned with CamScanner

ជាប់ចោទពីបទ: បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ដូរ កែច្នៃ តម្កើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត ភេទស្រី អាយុ៣៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិជំនាប់ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

## ៦រឿងហេតុមានដូចតទៅ:

កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ២០ និង២៥នាទី ស្ថិតនៅចំនុចខាងជើងផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានករណី លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ដូរ កែច្នៃ តម្កើងនូវអាវុធគ្រឿង ផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ តឹក សំអុល, ឈ្មោ[redacted]វុទ្ធី និងឈ្មោះ[redacted]យឿង ដែលបានធ្វើសកម្មភាពប្រើប្រាស់អាវុធម៉ាក AK ជាមធ្យោបាយបណ្តាលឲ្យជនរងគ្រោះឈ្មោះ [redacted] ជឿន ជាម្ចាស់ផ្ទះបានបាត់បង់ជីវិត។ ក្រោយពេលធ្វើសកម្មភាពជនត្រូវចោទទាំងបីខាងលើបានរត់គេចខ្លួនបាត់។ ចំពោះឈ្មោ[redacted]ម៉ុន្តា បានធ្វើសកម្មភាពលក់អាវុធម៉ាក AK ទៅឲ្យឈ្មោះ[redacted] សំអុល ហើយ ជននេះក៏បានយកទៅលក់ឲ្យឈ្មោះ [redacted]រី និងឈ្មោះ [redacted] អ៊ីន បន្តទៀត ដោយឡែកឈ្មោះ ឌី និងឈ្មោះ រ៉ាន់ ក៏មានជាប់ពាក់ពន្ធ័ជាមួយនិងឈ្មោះ [redacted] សំអុល ក្នុងការចែកចាយអាវុធដោយគ្មានការអនុញ្ញាតផងដែរ។ មុននិងធ្វើសកម្មភាពឈ្មោះ [redacted] ស្រីស្ទួគ៌ ជាប្រពន្ធរបស់ឈ្មោះ [redacted] សំអុល បានទិញម្ហូបអាហាររៀបចំបាយទឹក ហើយថែមទាំង ជូនឈ្មោះ[redacted]សំអុល ដោយជិះម៉ូតូទៅ ហើយក៏បានត្រលប់មកវិញមុនផងដែរ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ "ខ" ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ឲ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ស្រីស្ទួគ៌ ភេទស្រី អាយុ២២ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ) ពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ដូរ កែច្នៃ តម្កើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ៣៥៣, ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។



Scanned with CamScanner

២.ឲ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ម៉ុន្ថា ភេទប្រុស អាយុ៤៨ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ) ពីបទ: បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៣.ផ្តន្ទាទោសលើជនជាប់ចោទ:

ក.ឈ្មោះ [redacted] វុទ្ធី ហៅ ធី ភេទប្រុស អាយុ ៣៧ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ)។

ខ.ឈ្មោះ [redacted]យៀង ហៅ អាយួន ភេទប្រុស អាយុ ៣៥ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ)។

ម្នាក់ៗដាក់ពន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៤.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ៣២ឆ្នាំ (មានសវតាជាតិដូចខាងលើ) ដាក់ពន្ធនាគាររយៈពេល ២៥ឆ្នាំ ពីបទ: លួចមានស្ថានទម្ងន់ទោស ដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុចភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៥.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី ភេទប្រុស អាយុ ៣៧ឆ្នាំ, ឈ្មោះ [redacted]យៀង ហៅ អាយួន ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ ៣២ឆ្នាំ សងសំណងជម្ងឺចិត្តចំនួន ៣០.០០០.០០០ (សាមសិបលាន)រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសាលក្រមចូលជាស្ថាពរ។

៦.បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted]សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ៣២ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ)។

៧.វត្ថុតាងដែលមានក្នុងកំណត់ទទួលវត្ថុតាងរួមមាន:

-កាំភ្លើងចំនួនអាកា(AK) ៤ចំនួនដើម ស្នាយបត់ចំនួន ០១ដើម មានលេខតួ ១៦២៣៤៣២ និងស្នាយកាត់៣ដើម មានលេខតួ ៥៣១៩៩៥៤, លេខតួ ៥៣១៨៨៤១, លេខតួ ៥៣២១៥៥២, បង់ចំនួន ០៤បង់, គ្រាប់ចំនួន៨៦គ្រាប់ ស្នាប់ដៃចំនួន ០២, ស្នាយដោះចេញចំនួន ០២, គល់អុសចំនួន ០២កំណាត់ ធុងប៉េត្រូចំនួន ០១ពណ៌ស



Scanned with CamScanner

សង្កសីមួយផ្ទាំង,  ពិល ០១ពណ៌ក្រហម, ដង្កាប់ ០២, ក្តារកិតបោ ២ ដំរពណ៌ខៀវ, ស្លាបព្រាដែករៀបឥដ្ឋ ០១, កន្ត្រៃកាត់ដែក០១, ដងកន្ត្រៃកាត់ដែក ០២, ម៉ែត្ររមូ ០១ ខួចពណ៌ខៀវ, អាវប៉ារ៉ាដៃវែង ០២, ខោប៉ារ៉ាជើងវែង ០១, ខ្សែកាំភ្លើង ០២, ស្បែកជើងផ្ទាត់ ០៣គូ, ស្បែកជើងបាត់តា ០១គូ ក្រណាត់ខោជើងវែង ០២, អាវយឺតដៃខ្លីពណ៌ក្រហម០១, មួកយឺតពណ៌ខ្មៅក្រៅក្រហមក្នុង ០១, ខោលីអូពណ៌ខៀវ ០១, អាវដៃវែងឆ្នូតពណ៌សលាយទឹកប៊ិច ០១ , ក្រណាត់កៅស៊ូ ពណ៌ស ០១ផ្ទាំង ថង់កាតេតពណ៌ស ០៣ ពណ៌លឿង ០១, ថង់ប្លាស្ទិចពណ៌ស ០១ ពណ៌លឿង ០១, សំបកគ្រាប់ធុន ៧៦២មម x ៣៩មម ចំនួន ០៣ សំបក មានលេខសំគាល់គូថ ២៧០ ពណ៌ទង់ដែងដូចគ្នា និង ដង្កាប់ដែក ០១, ដងស្រោមដំរពណ៌លឿងលាយខ្មៅ(សង្កាប់ថ្មី) សម្រេចរឹបអូសទុកជាសម្បត្តិ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ទ្ធី ហៅ ធី, ឈ្មោះ[redacted]យឿង ហៅ អាយួន, ឈ្មោះ [redacted]ស្រីស្ទូគី, ឈ្មោះ [redacted]ម៉ុន្តា និងកំបាំងមុខជនចាប់ចោទឈ្មោះ [redacted]សំអុល ហៅ [redacted] សំអុល និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ: ៧៨ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ[redacted]យឿង និងឈ្មោះ [redacted]វុទ្ធី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ "ខ" ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ  របាយការណ៍រឿង ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]ទ្ធី (វត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted]យឿង (វត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុណាត (អវត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ[redacted]វុទ្ធី បានឆ្លើយសារភាពថា: ចំពោះការចោទប្រកាន់លើខ្លួនពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ  ខ្លួនទទួលស្គាល់ថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ [redacted]សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាសឈ្មោះ[redacted] ជឿន ហើយពេលទៅប្លន់នោះ ឈ្មោះ [redacted]សំអុល និងឈ្មោះ [redacted]យឿង បានកាន់កាំភ្លើងម្នាក់មួយដើម រីឯខ្លួនមិនមានកាន់

អ្វីទេ។ ពេលទៅដល់ផ្ទះរបស់ជាងមាស ឈ្មោះ [redacted] សំអុល បានកាត់របងលួសចំនួន ១ខ្សែ រួចត្បរចូលមុន ហើយខ្លួនដើរចូលតាមក្រោយ ដោយឈ្មោះ [redacted] យឿង នៅចាំខាងក្រៅ។ ពេលចូលទៅដល់ក្រោយផ្ទះ ឈ្មោះ [redacted] សំអុល បានប្រតាយប្រតប់ជាមួយជាងមាស ហើយឈ្មោះ [redacted] សំអុល បានបាញ់ជាងមាសចំនួន ពីរគ្រាប់ បន្ទាប់មកពួកខ្លួនក៏នាំគ្នារត់ចេញ។ រីឯបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ផ្តល់ កែច្នៃ តម្លើង នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ខ្លួនមិនបានប្រព្រឹត្តទេ។ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយកន្លងមក។ ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារតែសាលាដំបូងខេត្តកំពង់ស្ពឺផ្តន្ទាទោសខ្លួនធ្ងន់ពេក។

សំណូមពរ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] យឿង បានឆ្លើយសារភាពថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារសាលាដំបូងខេត្តកំពង់ស្ពឺដាក់ទោសខ្លួនធ្ងន់ពេក។ ខ្លួនទទួលស្គាល់ថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយនៅមុនពេលកើតហេតុចំនួន បីថ្ងៃ ឈ្មោះ តឹក សំអុល បានខលមកបបួលខ្លួនទៅប្លន់ផ្ទះជាងមាស ដំបូងឡើយខ្លួនក៏បានប្រកែកដែរ ប៉ុន្តែនៅពេលរសៀលថ្ងៃកើតហេតុទី១៥ ខែមករា ឆ្នាំ២០១៦ ឈ្មោះ [redacted] សំអុល បានហៅខ្លួនទៅផឹកនៅផ្ទះវា ដោយសារតែខ្លួនផឹកស្រាស្រវឹងភ្លេចស្មារតី ខ្លួនក៏បានចូលរួមសមគំនិតជាមួយឈ្មោះ [redacted] សំអុល ទៅប្លន់ផ្ទះជាងមាស។ ពេលទៅប្លន់នោះ ឈ្មោះ [redacted] សំអុល និងខ្លួនបានកាន់កាំភ្លើងម្នាក់មួយដើម ប៉ុន្តែខ្លួនមិនបានចូលទៅក្នុងផ្ទះរបស់ជនរងគ្រោះទេ គឺខ្លួននៅឈរខាងក្រៅ ដោយឈ្មោះ [redacted] សំអុល និងឈ្មោះ [redacted] វុទ្ធី ជាអ្នកចូល។ ពេលនោះជនរងគ្រោះកំពុងតែនៅក្រោយផ្ទះ ហើយឈ្មោះ [redacted] សំអុល ចូលទៅដល់បានក្តាប់កាំភ្លើងជនរងគ្រោះ និងមានការប្រតាយប្រតប់គ្នារហូតដល់មានការផ្ទុះកាំភ្លើងចំនួន ពីរគ្រាប់ ដោយឈ្មោះ [redacted] សំអុល ជាអ្នកបាញ់។ បន្ទាប់មកឮម្ចាស់ផ្ទះស្រែកថា ចោរៗ ចោរប្លន់ និងមានអ្នកភូមិមកកុះករ ខ្លួនក៏បានបាញ់មួយគ្រាប់ទៀត ដើម្បីបង្អើលឱ្យអ្នកភូមិរត់ចេញ ហើយខ្លួន និងបក្ខពួកក៏បានរត់ចេញតែម្តង។ ខ្លួនមានចេតនាត្រឹមតែទៅប្លន់ប៉ុណ្ណោះ ពុំមានចេតនាទៅបាញ់សម្លាប់ទេ ចំពោះកាំភ្លើងចំនួន ០២ដើមនោះ គឺជារបស់ឈ្មោះ [redacted] សំអុល ហើយការប្លន់នោះពុំបានសម្រេច ទេ។ ក្រោយមករំលងបាន ពីរខែ ទើបសមត្ថកិច្ចស្រាវជ្រាវចាប់ពួកខ្លួនបាន ខ្លួនបានដឹងកំហុស និងកែប្រែខ្លួនហើយ។

សំណូមពរ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត បានឆ្លើយនាពេលសវនាការនៅសាលាដំបូងខេត្តកំពង់ស្ពឺថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៦ជាងល្ងាច ខ្លួនកំពុងនៅខាងមុខផ្ទះជាមួយកូន ហើយប្តីរបស់ខ្លួននៅដងទឹកខាងក្រោយផ្ទះ ពេលនោះបានឮសំឡេងប្តីរបស់ខ្លួនស្រែកថា ចោរប្លន់ហើយ ពេលនោះខ្លួនក៏បានរត់ទៅមើល តែពេលទៅដល់ប្តីរបស់ខ្លួនដេកដួលនៅនឹងដីទៅហើយ។ ខ្លួនបាននាំគាត់ទៅដល់មន្ទីរពេទ្យ ប្តីរបស់ខ្លួនក៏បានស្លាប់។ ខ្លួនទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]ពយ បានឆ្លើយនាពេលសវនាការនៅសាលាដំបូងខេត្តកំពង់ស្ពឺថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៧ និង៣០នាទីល្ងាច ខ្លួនកំពុងតែអង្គុយមើលទូរទស្សន៍ ស្រាប់តែប្រជាការពារភូមិឈ្មោះ [redacted]ប៊ិយ បានទូរស័ព្ទមកប្រាប់ថា មានគេប្លន់ក្នុងភូមិ ពេលឮដូច្នេះខ្លួនក៏ជិះម៉ូតូទៅកន្លែងកើតហេតុតែម្តង។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនមិនបានឃើញជនរងគ្រោះទេ ព្រោះជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យបាត់ទៅហើយៗខ្លួនក៏ការពារផ្ទះរបស់ជនរងគ្រោះរហូតទល់ភ្លឺ ទើបពួកខ្លួនត្រឡប់មកផ្ទះរៀងៗខ្លួន រឿងអ្វីទៀតខ្លួនមិនបានដឹងនោះទេ។ គ្រាន់តែនៅពេលទៅកន្លែងកើតហេតុនោះខ្លួនបានជិះកាត់មុខផ្ទះរបស់ឈ្មោះ [redacted]ស្រីស្ងួត ហើយបានឃើញឈ្មោះ[redacted]ស្រីស្ងួត នៅផ្ទះ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រ៉ាត់ បានឆ្លើយនៅចៅក្រមស៊ើបសួរថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោង ៨ និង ០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ ស្រាប់តែឮសំឡេងគេវាយគ្នា ពេលឮដូច្នេះខ្លួនក៏បើកបង្អួចមើលក៏ឃើញគេវាយគ្នា ខ្លួនក៏បិទបង្អួចទៅ ព្រោះខ្លាចគេបាញ់ត្រូវខ្លួន ហើយគេវាយគ្នានោះមានគ្នាប៉ុន្មាននាក់ ខ្លួនមិនបានដឹងទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]ហាន បានឆ្លើយនៅចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងតែក្រាលកន្ទេលដេក ស្រាប់តែឮសំឡេងស្រែកថា ជួយផងៗ ក្រោយមកឮសូរផ្ទុះ តែខ្លួនស្មានតែគេបាញ់ផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមនុស្សម្នាក់ពាក់អាវប៉ារ៉ាដៃវែង ឈរកាន់កាំភ្លើងវែង។ ពេលឃើញដូច្នេះ ខ្លួនក៏ស្រែកឱ្យគេជួយ រួចមកវាក៏បាញ់សំដៅទៅជនរងគ្រោះមួយគ្រាប់ទៀត រួចវាក៏រត់ទៅក្រោយផ្ទះជនរងគ្រោះបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គីមស៊ាង បានឆ្លើយនៅចៅក្រមស៊ើបសួរថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ ស្រាប់តែឮសំឡេងកាំភ្លើងគេបាញ់ចំនួន ៣គ្រាប់ ពេលឮដូច្នេះខ្លួនស្មានតែគេអុជផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមនុស្សចំនួន ៣នាក់ ម្នាក់ពាក់ខ្មៅដៃកាន់កាំភ្លើង និងពីរនាក់ទៀត ឃើញចេញមកពីក្នុងផ្ទះបាយ ពេលនោះក៏ឮសំឡេងឈ្មោ[redacted]ស៊ីណាត ស្រែកថា ជួយៗ ចោរប្លន់ហើយៗ ពេលឮដូច្នេះខ្លួនក៏រត់ទៅផ្ទះបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]សុភណ្ឌ័ បានឆ្លើយនៅចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងនៅផ្ទះបម្រុងនឹងងូតទឹកក៏ឮសំឡេងផាំងៗចំនួន ២ដង ខ្លួនស្មានតែសំឡេងគេបាញ់ផាវ ក៏ចេញមកក្រៅផ្ទះមើល ពេលចេញមកមើលឮសំឡេងឈ្មោះ [redacted]ាន ស្រែកថា ចោរៗ ចោរបាញ់ជាងមាសហើយ ពេលឮដូច្នេះខ្លួនក៏នាំកូនរត់ចូលផ្ទះបាត់ទៅ។ ពេលកើតហេតុហើយបានប្រហែលជាកន្លះម៉ោង ខ្លួនក៏រត់ទៅមើលផ្ទះជនរងគ្រោះ ពេលទៅដល់ឃើញប្តីរបស់ឈ្មោះ[redacted]ស៊ីណាត ដេកដួលនៅគៀនរោងបាយ បានមួយសន្ទុះក្រោយមក ប្រពន្ធរបស់ជនរងគ្រោះក៏បញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យតែម្តង។

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានថា: ឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី បានជាប់ចោទពីបទលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ខ្ចី ផ្ទេរ ចែកចាយ ផ្តល់ កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។ នៅក្នុងរឿងនេះ ជនជាប់ចោទបានរៀបចំគម្រោងផែនការ និងមានការចាត់តាំងច្បាស់លាស់ដោយមានការបំពាក់អាវុធ ដែលអំពើល្មើសនេះបានធ្វើឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ បង្កអសន្តិសុខសង្គម និងធ្វើឱ្យប្រជាជនមានការភ័យខ្លាច។ តំណាងមហាអយ្យការយល់ឃើញថា ការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលបានផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី ដាក់ពន្ធនាគារម្នាក់ៗចំនួន ២០ (ម្ភៃ)ឆ្នាំ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ទណ្ឌកម្មទុកជាបានការដដែល។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនទាំងពីរនាក់ បានឆ្លើយសារភាព និងទទួលស្គាល់រួចហើយថា ពួកគាត់ពិតជាបានចូលរួមប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះប្រាកដមែន ប៉ុន្តែកូនក្តីខ្លួនពុំមែនជាអ្នកបាញ់សម្លាប់ជនរងគ្រោះទេ ហើយកូនក្តីខ្លួនក៏ពុំមានឆន្ទៈទៅបាញ់ដែរ គឺជាឆន្ទៈរបស់ឈ្មោះ [redacted] សំអុល ជាអ្នកបាញ់ជនរងគ្រោះ។ កូនក្តីខ្លួនទាំងពីរនាក់បានឆ្លើយសារភាព និងដឹងកំហុសហើយ បង្កការងាយស្រួលដល់អង្គសវនាការ ដោយសន្យានឹងកែប្រែខ្លួនឡើងវិញ ដូច្នេះខ្លួនស្នើសុំឱ្យតុលាការមេត្តាពិចារណា និងសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនទាំងពីរនាក់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យឿង ធ្វើសេចក្តីសន្និដ្ឋានថា: អំពើល្មើសប្លន់ដែលបានកើតឡើងនៅក្នុងរឿងនេះ គឺជាគំនិតផ្តួចផ្តើមរបស់ឈ្មោះ [redacted] សំអុល តែម្នាក់គត់ ព្រោះតាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយថា នៅមុនពេលប្រព្រឹត្តបទល្មើស ឈ្មោះ [redacted] សំអុល បានខលបបួល បង្ខិតបង្ខំ និងជម្រុយខ្លួនឱ្យទៅប្រព្រឹត្តអំពើប្លន់នេះ។ ម្យ៉ាងទៀត តាមភស្តុតាងបានបញ្ជាក់ថា អាវុធទាំងអស់គឺ ជារបស់ឈ្មោះ តឹក សំអុល ហើយកូនក្តីខ្លួនក៏ពុំមានបំណង ឬឆន្ទៈសម្លាប់ជនរងគ្រោះក្នុងពេលប្លន់ដែរ តែការសម្លាប់ជនរងគ្រោះនោះគឺ ស្តែងចេញឡើងដោយឆន្ទៈរបស់ឈ្មោះ [redacted] សំអុល។ ការប្រព្រឹត្តរបស់កូនក្តីខ្លួនកើតឡើងដោយសារកាលៈទេសបង្ខំ ដូច្នេះយោងតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ខ្លួនស្នើសុំឱ្យតុលាការពិចារណាទៅលើកាលៈទេសនៃការប្រព្រឹត្ត និងផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

error of fact



Scanned with CamScanner

# សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍លេខ: ៧៨ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted]យឿង និងឈ្មោះ [redacted] វុទ្ធី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ “ខ” ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទទួលសំណុំរឿងខាងលើនេះជំនុំជម្រះបាន យោងតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, មាត្រា ៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមលទ្ធផលនៃកិច្ចពិភាក្សាសួរដេញដោលឃើញថា: ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយសារភាពថា ចំពោះការចោទប្រកាន់លើខ្លួនពីបទ លួចមានស្ថាន ទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ ខ្លួនទទួលស្គាល់ថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ[redacted] សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាសឈ្មោ[redacted]ជឿន ហើយពេលទៅប្លន់នោះ ឈ្មោះ [redacted]សំអុល និងឈ្មោះ[redacted] យឿង បានកាន់កាំភ្លើងម្នាក់មួយដើម រីឯខ្លួនមិនមានកាន់អ្វីទេ។ ពេលទៅដល់ផ្ទះរបស់ជាងមាស ឈ្មោះ [redacted]សំអុល បានកាត់របងលួសចំនួន ១ខ្សែ រួចត្បូរចូលមុន ហើយខ្លួនដើរចូលតាមក្រោយ ដោយឈ្មោះ [redacted]យឿង នៅចាំខាងក្រៅ។ ពេលចូលទៅដល់ក្រោយផ្ទះ ឈ្មោះ [redacted] សំអុល បានប្រតាយប្រតប់ជាមួយជាងមាស ហើយឈ្មោះ តឹក សំអុល បានបាញ់ជាងមាសចំនួន ពីរគ្រាប់ បន្ទាប់មកពួក ខ្លួនក៏នាំគ្នារត់ចេញ។ រីឯបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ខ្លួនមិនបានប្រព្រឹត្តទេ។ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយកន្លងមក ហើយខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារតែសាលាដំបូងខេត្តកំពង់ស្ពឺផ្តន្ទាទោសខ្លួនធ្ងន់ពេក។

សំណូមពរ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted]យឿង បានឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដោយសារសាលាដំបូងខេត្តកំពង់ស្ពឺដាក់ទោសខ្លួនធ្ងន់ពេក។ ខ្លួនទទួលស្គាល់ថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយនៅមុនពេល កើតហេតុចំនួន បីថ្ងៃ ឈ្មោះ [redacted]សំអុល បានខលមកបបួលខ្លួនទៅប្លន់ផ្ទះជាងមាស ដំបូងឡើយខ្លួនក៏បានប្រកែកដែរ ប៉ុន្តែនៅពេលរសៀលថ្ងៃកើតហេតុទី១៥ ខែមករា ឆ្នាំ២០១៦ ឈ្មោះ [redacted]សំអុល បានហៅខ្លួនទៅផឹកនៅផ្ទះវា ដោយសារតែខ្លួនផឹកស្រាស្រវឹងភ្លេចស្មារតី ខ្លួនក៏បានចូលរួមសមគំនិតជាមួយឈ្មោះ [redacted] សំអុល ទៅប្លន់ផ្ទះជាងមាស។ ពេលទៅប្លន់នោះ ឈ្ម[redacted]សំអុល និងខ្លួនបានកាន់កាំភ្លើងម្នាក់មួយដើម ប៉ុន្តែខ្លួនមិនបានចូលទៅក្នុងផ្ទះ របស់ជនរងគ្រោះទេ គឺខ្លួននៅឈរខាងក្រៅ ដោយឈ្មោះ[redacted] សំអុល និងឈ្មោះ [redacted]ទ្ធី ជាអ្នកចូល។ ពេលនោះជនរងគ្រោះកំពុងតែនៅក្រោយផ្ទះ ហើយឈ្មោះ [redacted] សំអុល ចូលទៅដល់បានភ្លុងកាំភ្លើងជនរងគ្រោះ និងមានការប្រតាយប្រតប់គ្នារហូតដល់មានការផ្ទុះកាំភ្លើងចំនួន ពីរគ្រាប់ ដោយឈ្មោះ [redacted] សំអុល ជាអ្នកបាញ់។ បន្ទាប់មកឮម្ចាស់ផ្ទះស្រែកថា ចោរៗ ចោរប្លន់ និងមានអ្នកភូមិមកកុះករ ខ្លួនក៏បានបាញ់មួយគ្រាប់ទៀត ដើម្បីបង្អើលឱ្យអ្នកភូមិរត់ចេញ ហើយខ្លួន និងបក្ខពួកក៏បានរត់ចេញតែម្តង។ ខ្លួនមានចេតនាត្រឹមតែទៅប្លន់ប៉ុណ្ណោះ



Scanned with CamScanner

ពុំមានចេតនាទៅបាញ់សម្លាប់ទេ ចំពោះកាំភ្លើងចំនួន ០២ដើមនោះ គឺជារបស់ឈ្មោះ [redacted] សំរុល ហើយការប្លន់នោះពុំបានសម្រេចទេ។ ក្រោយមកវិលងបាន ពីរខែ ទើបសមត្ថកិច្ចស្រាវជ្រាវចាប់ពួកខ្លួនបាន ខ្លួនបានដឹងកំហុសនិងកែប្រែខ្លួនហើយ។

សំណូមពរ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា។

៣-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត បានឆ្លើយថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៦ជាងល្ងាច ខ្លួនកំពុងនៅខាងមុខផ្ទះជាមួយកូន ហើយប្តីរបស់ខ្លួននៅរងទឹកខាងក្រោយផ្ទះ ពេលនោះបានឮសំឡេងប្តីរបស់ខ្លួនស្រែកថា ចោរប្លន់ហើយ ពេលនោះខ្លួនក៏បានរត់ទៅមើល តែពេលទៅដល់ប្តីរបស់ខ្លួនដេកដួលនៅនឹងដីទៅហើយ។ ខ្លួនបាននាំគាត់ទៅដល់មន្ទីរពេទ្យ ប្តីរបស់ខ្លួនក៏បានស្លាប់។ ខ្លួនទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា។

៤-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ពយ បានឆ្លើយថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៧ និង៣០នាទីល្ងាច ខ្លួនកំពុងតែអង្គុយមើលទូរទស្សន៍ ស្រាប់តែប្រជាការពារភូមិឈ្មោះ [redacted] ប៊ិយ បានទូរស័ព្ទមកប្រាប់ថា មានគេប្លន់ក្នុងភូមិ ពេលឮដូច្នេះខ្លួនក៏ជិះម៉ូតូ ទៅកន្លែងកើតហេតុតែម្តង។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនមិនបានឃើញជនរងគ្រោះទេ ព្រោះជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យបាត់ទៅហើយ ខ្លួនក៏ការពារផ្ទះរបស់ជនរងគ្រោះរហូតទល់ភ្លឺ ទើបពួកខ្លួនត្រឡប់មកផ្ទះរៀងៗខ្លួន រឿងអ្វីទៀតខ្លួនមិនបានដឹងនោះទេ។ គ្រាន់តែនៅពេលទៅកន្លែងកើតហេតុនោះខ្លួនបានជិះកាត់មុខផ្ទះរបស់ឈ្មោះ [redacted] ស្រីស្ងួត ហើយបានឃើញឈ្មោះ [redacted] ស្រីស្ងួត នៅផ្ទះ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រ៉ាត់ បានឆ្លើយថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោង ៨ និង ០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ ស្រាប់តែឮសំឡេងគេវាយគ្នា ពេលឮដូច្នេះខ្លួនក៏បើកបង្អួចមើលក៏ឃើញគេវាយគ្នា ខ្លួនក៏បិទបង្អួចទៅ ព្រោះខ្លាចគេបាញ់ត្រូវខ្លួន ហើយគេវាយគ្នានោះមានគ្នាប៉ុន្មាននាក់ ខ្លួនមិនបានដឹងទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ហាន បានឆ្លើយថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងតែក្រាលកន្ទេលដេក ស្រាប់តែឮសំឡេងស្រែកថា ជួយផងៗ ក្រោយមកឮស្គរផ្ទុះ តែខ្លួនស្មានតែគេបាញ់ផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមនុស្សម្នាក់ពាក់អាវប៉ាក់ដៃវែង ឈរកាន់កាំភ្លើងវែង។ ពេលឃើញដូច្នេះ ខ្លួនក៏ស្រែកឱ្យគេជួយ រួចមកវាក៏បាញ់សំដៅទៅជនរងគ្រោះមួយគ្រាប់ទៀត រួចវាក៏រត់ទៅក្រោយផ្ទះជនរងគ្រោះបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គីមស៊ាង បានឆ្លើយថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ ស្រាប់តែឮសំឡេងកាំភ្លើងគេបាញ់ចំនួន ៣គ្រាប់ ពេលឮដូច្នេះខ្លួនស្មានតែគេអុជផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមនុស្សចំនួន ៣នាក់ ម្នាក់ពាក់ខ្សៅដៃ កាន់កាំភ្លើង និងពីរនាក់

ទៀត ឃើញចេញមកពីក្នុងផ្ទះបាយ ពេលនោះក៏ឮសំឡេងឈ្មោះ [redacted] ស៊ីណាត ស្រែកថា ជួយៗ ចោរប្លន់ហើយៗ ពេលឮដូច្នេះខ្លួនក៏រត់ទៅផ្ទះបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភណ្ឌ័ បានឆ្លើយថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៧ និង០០នាទី ខ្លួនកំពុងនៅផ្ទះបម្រុងនឹងងូតទឹកក៏ឮសំឡេងផាំងៗចំនួន ២ដង ខ្លួនស្មានតែសំឡេងគេបាញ់ផាវ ក៏ចេញមកក្រៅផ្ទះមើល ពេលចេញមកមើលឮសំឡេងឈ្មោះ [redacted]ហាន ស្រែកថា ចោរៗ ចោរបាញ់ជាងមាសហើយ ពេលឮដូច្នេះខ្លួនក៏នាំកូនរត់ចូលផ្ទះបាត់ទៅ។ ពេលកើតហេតុហើយបាន ប្រហែលជាកន្លះម៉ោង ខ្លួនក៏រត់ទៅមើលផ្ទះជនរងគ្រោះ ពេលទៅដល់ឃើញប្តីរបស់ឈ្មោះ [redacted] ស៊ីណាត ដេកដួលនៅជៀនរោងបាយ បានមួយសន្ទុះក្រោយមក ប្រពន្ធរបស់ជនរងគ្រោះក៏បញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យតែម្តង។

គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា។

៥-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: ឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី បានជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។ នៅក្នុងរឿងនេះ ជនជាប់ចោទបានរៀបចំគម្រោងផែនការ និងមានការចាត់តាំងច្បាស់លាស់ ដោយមានការបំពាក់អាវុធ ដែលអំពើល្មើសនេះបានធ្វើឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ បង្កអសន្តិសុខសង្គម និងធ្វើឱ្យប្រជាជនមានការភ័យខ្លាច។ តំណាងមហាអយ្យការយល់ឃើញថា ការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលបានផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី ដាក់ពន្ធនាគារម្នាក់ៗចំនួន ២០ (ម្ភៃ)ឆ្នាំ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ទណ្ឌកម្មទុកជាបានការដដែល។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា។

៦-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យឿង និងឈ្មោះ [redacted] វុទ្ធី ថា: កូនក្តីខ្លួនទាំងពីរនាក់ បានឆ្លើយសារភាព និងទទួលស្គាល់រួចហើយថា ពួកគាត់ពិតជាបានចូលរួមប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះប្រាកដមែន ប៉ុន្តែកូនក្តីខ្លួនពុំមែនជាអ្នកបាញ់សម្លាប់ជនរងគ្រោះទេ ហើយកូនក្តីខ្លួនក៏ពុំមានឆន្ទៈទៅបាញ់ដែរ គឺជាឆន្ទៈរបស់ឈ្មោះ [redacted] សំអុល ជាអ្នកបាញ់ជនរងគ្រោះ។ កូនក្តីខ្លួនទាំងពីរនាក់បានឆ្លើយសារភាព និងដឹងកំហុសហើយ បង្កការងាយស្រួលដល់អង្គសវនាការ ដោយសន្យានឹងកែប្រែខ្លួនឡើងវិញ ដូច្នេះខ្លួនស្នើសុំឱ្យតុលាការមេត្តាពិចារណា និងសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនទាំងពីរនាក់។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យឿង ថា: អំពើល្មើសប្លន់ដែលបានកើតឡើងនៅក្នុងរឿងនេះ គឺជាគំនិតផ្តួចផ្តើមរបស់ឈ្មោះ [redacted] សំអុល តែម្នាក់គត់ ព្រោះតាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយថា នៅមុនពេលប្រព្រឹត្តបទល្មើស ឈ្មោះ [redacted] សំអុល បានខលបបួល បង្ខិតបង្ខំ និងជម្រុយខ្លួនឱ្យទៅប្រព្រឹត្តអំពើប្លន់នេះ។ ម្យ៉ាងទៀត តាមភស្តុតាងបានបញ្ជាក់ថា អាវុធទាំងអស់គឺ ជារបស់ឈ្មោះ [redacted]



Scanned with CamScanner

សំអុល ហើយកូនក្តីខ្លួនក៏ពុំមានបំណង ឬឆន្ទៈសម្លាប់ជនរងគ្រោះក្នុងពេលប្លន់ដែរ តែការសម្លាប់ជនរងគ្រោះនោះគឺស្តែងចេញឡើងដោយឆន្ទៈរបស់ឈ្មោះ [redacted] សំអុល។ ការប្រព្រឹត្តរបស់កូនក្តីខ្លួនកើតឡើងដោយសារកាលៈទេសៈបង្ខំ ដូច្នេះយោងតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ខ្លួនស្នើសុំឱ្យតុលាការពិចារណាទៅលើកាលៈទេសៈនៃការប្រព្រឹត្ត និងផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន។

គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា។

៧-សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា: តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ឃឿង ថា ចំពោះបទល្មើសបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ខ្លួនមិនបានប្រព្រឹត្តទេ នោះគ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះ ជនជាប់ចោទពុំមានភស្តុតាងដោះបន្ទុកឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញជឿបានឡើយ។ រីឯតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] ឃឿង មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត, សាក្សីឈ្មោះ [redacted] ពយ ឈ្មោះ [redacted] រ៉ាត់ ឈ្មោះ [redacted] ហាន ឈ្មោះ [redacted] គីមស៊ាង និងឈ្មោះ [redacted] សុភណ្ឌ័, របាយការណ៍សំយោគលេខ ០៥៥ រ/ប/ក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ របស់ការិយាល័យកណ្តាលនគរបាលព្រហ្មទណ្ឌ និងភស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿងដូចជា វត្ថុតាងកាំភ្លើងអាកា (AK) ចំនួន ០៤ដើម, បង់ចំនួន ០៤បង់, គ្រាប់ចំនួន ៨៦គ្រាប់, កន្ត្រៃកាត់ដែកចំនួន ០១ និងដងកន្ត្រៃកាត់ដែកចំនួន ០២។ អំពើខាងលើនេះ បង្ហាញឱ្យឃើញនូវពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ឃឿង និងឈ្មោះ [redacted] វុទ្ធី ពីបទ លួចមានស្ថានទម្ងន់ទោស ដោយសារមរណៈភាពជនរងគ្រោះ និង បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ដែលបំពានមាត្រា ៣៥៣ មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ និងសន្តិសុខសង្គមយ៉ាងធ្ងន់ធ្ងរ ដូច្នេះសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ គប្បីប្រកាសផ្តន្ទាទោសជនជាប់ចោទទាំងពីររូបនេះតាមច្បាប់។ ដូចមានបញ្ជាក់នៅក្នុងផ្នែកសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ “ខ” ចុះថ្ងៃ ទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺស្រាប់ សាលាឧទ្ធរណ៍ភ្នំពេញឯកភាពតាមសំអាងហេតុនៃសាលក្រមនេះ សាលាឧទ្ធរណ៍ភ្នំពេញពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតឡើយ។

៨-សាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ “ខ” ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមខាងលើនេះ ទុកជាបានការដដែល។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ: ៧៨ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ឃឿង និងឈ្មោះ [redacted] វុទ្ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

138/1

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ២៥៩ "ខ" ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឃឿង និងឈ្មោះ [redacted] វុទ្ធី តាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឃឿង និងឈ្មោះ [redacted] វុទ្ធី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner